# ការគ្រប់គ្រងដែលផ្តោតលើលទ្ធផល Results-Based Management

ដោយ ឡេង ឆាយ

## និយមន័យ

- ផ្តោតទៅលើការតាមដាន**ដំណើរការផ្លាស់ប្តូរ**សំរាប់រយៈពេលខ្លី មធ្យម និងរយៈពេលវែង។
- ជាច្រវាក់លទ្ធផលដែលមានការទាក់ទងគ្នា។
- មិនសួរចង់ដឹងថាត្រូវធ្វើអ្វីនោះទេ ប៉ុន្តែចង់ដឹងថាមានអ្វីប្រែប្រួល។




## ១.ទស្សនៈវិស័យរបស់កម្មវិធី

- ជារូបភាពនៃជោគជ័យរបស់កម្មវិធី
- ឆ្លើយនឹងសំនួរដូចជា៖
  - តើមានការប្រែប្រួលអ្វីខ្លះកើតឡើង?
  - តើក្រុមគោលដៅរបស់អ្នកកំពុងធ្វើអ្វី? ធ្វើរបៀបណា?
  - តើអង្គការដៃគូរបស់អ្នកកំពុងធ្វើអ្វី?
- ចូរពណ៌នាអំពីពិភពលោកប្រសើរមួយដែលអ្នក កំពុងស្វែងរក?

## ២.បេសកកម្មរបស់កម្មវិធី

- ជាផ្នែកមួយនៃឃ្លាទស្សនៈវិស័យដែលកម្មវិធីនឹងផ្តោតទៅលើវា៖
  - តើអ្នកនឹងធ្វីអ្វី?
  - អ្នកណាជាក្រុមគោលដៅ ឬអ្នកសហការរបស់អ្នក?
  - តើអ្នកនឹងធ្វើការជាមួយគេដោយវិធីណា?

(Your mission = your business)

This learning article shared by Cambodian Learning Facilitators (www.camlefa.org). All rights reserved.

## ៣.ឥទ្ធិពលវែង Impact

- ផ្តោតលើរយៈពេលវែង។
- ជាផលប៉ះពាល់ទូលំទូលាយរបស់គំរោង។
- ផ្តោតលើសហគមន៍ឬសង្គមៈ ជាការប្រែប្រួលលក្ខខ័ណ្ឌឬស្ថានភាពសង្គម។

## ៤.ឥទ្ធិពលមធ្យម Outcomes

- ជាការប្រែប្រួលរយៈពេលមធ្យម ។
- សំដៅលើការប្រែប្រួល អាកប្បកិរិយា ទំនាក់ទំនង និងសកម្មភាព របស់បុគ្គល និងអង្គការដែលគំរោងធ្វើជាមួយផ្ទាល់។

## ៥.ទិន្នផល Outputs

- ជាលទ្ធផលភ្លាមៗចេញពីសកម្មភាព
- ជាផលិតផលឬសេវាដែលអ្នកបានផ្តល់

សូមអ្នកមើលឧទាហរណ៍ខាងក្រោម

This learning article shared by Cambodian Learning Facilitators (www.camlefa.org). All rights reserved.

## ឧទាហរណ៍

| | |
|---|---|
| **ឥទ្ធិពលវែង**<br>Impact | ប្រជាពលរដ្ឋមានសុវត្ថិភាពសេ្បៀង មានលំនៅដ្ឋានរស់នៅសមរម្យ មានសុខភាពល្អ កូនបានចូលសាលារៀនយ៉ាងតិចរៀនចប់អនុវិទ្យាល័យ។ |
| **ឥទ្ធិពលមធ្យម**<br>Outcomes | ចំណូលរបស់ប្រជាពលរដ្ឋពីមុខរបរខ្នាតតូចកើនឡើង។ ប្រជាពលរដ្ឋមានទំនុចិត្តក្នុងការគ្រប់គ្រងមុខរបរខ្នាតតូច ហើយរបររកស៊ីរបស់គេទទួលបានជោគជ័យ។ |
| **ទិន្នផល**<br>Outputs | ប្រជាពលរដ្ឋបានយល់ដឹងពីវិធីគ្រប់គ្រងរបរខ្នាតតូច។ ប្រជាពលរដ្ឋមានលទ្ធភាពខ្ចីឥណទានដែលមានអត្រាការប្រាក់ទាបសំរាប់ធ្វើដើមទុនរកស៊ី។ |
| **សកម្មភាព**<br>Activities | ផ្តល់ការបណ្តុះបណ្តាល និងប្រឹក្សាយោបល់ អំពីវិធីគ្រប់គ្រងមុខរបរខ្នាតតូចដល់ប្រជាពលរដ្ឋ។ ផ្តល់ឥណទានដែលមានអត្រាការប្រាក់ទាបដល់ប្រជាពលរដ្ឋសំរាប់ធ្វើដើមទុនរកស៊ី។ |

This learning article shared by Cambodian Learning Facilitators (www.camlefa.org). All rights reserved.